ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## រោងចក្រកាត់ដេរ ហាណា(ខេមបូឌា) អ៊ីង.

អាស័យដ្ឋានៈ ផ្លូវជាតិលេខ៤ ភូមិអង្គកែវ សង្កាត់ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ភ្នំពេញថ្ងៃទី១៣ ខែ កញ្ញា ឆ្នាំ២០២១

# កិច្ចព្រមព្រៀងរួម
## ស្តីពី
## ការព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងនេះត្រូវបានរៀបចំធ្វើឡើងរវាងរោងចក្រកាត់ដេរ ហាណា(ខេមបូឌា) អ៊ីង ដែលកំណត់ជាភាគី(ក) និងតំណាងកម្មករ រោងចក្រ ហាណា(ខេមបូឌា) អ៊ីងដែលកំណត់ជាភាគី (ខ)។

ភាគីទាំងពីរបានព្រមព្រៀង និងឯកភាពគ្នាតាមប្រការ និងលក្ខ័ណ្ឌដូចខាងក្រោមៈ

**ប្រការ ១**

ក្រុមហ៊ុនស្នើរសុំព្យួរកិច្ចសន្យាការងាររយៈពេល៦១ថ្ងៃចាប់ពីថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២១ ដល់ថ្ងៃ ១៩ ខែ វិច្ឆិកា ឆ្នាំ ២០២១។ ដោយមូលហេតុក្រុមហ៊ុនយើងខ្ញុំគ្មានការបញ្ជាទិញ ដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១០១នាក់ (ស្រី ៧៨នាក់) ។

**ប្រការ ២**

ក្រុមហ៊ុនសម្រេចផ្តល់ជូនប្រាក់ឧបត្ថមសម្រាប់កម្មករនិយោជិតម្នាក់ៗក្នុង១ខែតាមប្រកាសរបស់ ក្រសួងការងារនឹងបណ្តុះបណ្តាលវជ្ជាជីវៈលេខ០៤៥/២០ ក.ប/ស.ណ.ន.ខ.លចុះកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ ក្នុងនោះ :

ចំនួន១០ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល៧ថ្ងៃដល់១០ថ្ងៃ។
ចំនួន២០ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល១១ថ្ងៃដល់២០ថ្ងៃ។
ចំនួន៣០ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល២១ថ្ងៃដល់១ខែ។

ទទួលបានប្រាក់ឧបត្ថមពីរាជរដ្ឋាភិបាលតាមរយៈភ្នាក់ងាររឹងដូចខាងក្រោមៈ
ចំនួន១៥ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល៧ថ្ងៃដល់១០ថ្ងៃ។
ចំនួន៣០ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល១១ថ្ងៃដល់២០ថ្ងៃ។
ចំនួន៤០ដុល្លាអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល២១ថ្ងៃដល់១ខែ។

**ប្រការ ៣**

កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ រហូតដល់មានការកែប្រែសារជាថ្មី។

ថ្ងៃច័ន្ទ ៧កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥
ធ្វើនៅភ្នំពេញ ថ្ងៃទី១៣ ខែ កញ្ញា ឆ្នាំ ២០២១

**ភាគី (ក) នាយកគ្រប់គ្រងរោងចក្រ**រោងចក្រ ហាណា(ខេមបូឌា) អ៊ីង

លោក **កូ ជុង ប៊ូម/ នាយកគ្រប់គ្រងរោងចក្រ**

**ភាគី(ខ) តំណាងកម្មករ រោងចក្រហាណា(ខេមបូឌា) អ៊ីង**

រៀល សុខា៉ | សោម ស៊ីឡូត | សៃ សុខឿន

ញឹម សុខណា | សេន ចន្ទូ | អឹម អេម